ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

នៅរសៀលថ្ងៃទី **២២** ខែ**សីហា** ឆ្នាំ២០១៨ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួប **ឯកឧត្តម** Mark Field អនុរដ្ឋមន្ត្រីការបរទេសនៃចក្រភពអង់គ្លេស ទទួលបន្ទុកតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដើម្បីសម្តែងការគួរសម និងពិភាក្សាការងារ ។

**ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានសំដែងនូវការស្វាគមន៍ ចំពោះដំណើរទស្សនកិច្ចរបស់ ឯកឧត្តម Mark Field ហើយបានស្វាគមន៍អំពីការប្តេជ្ញាចិត្តរបស់អង់គ្លេស ដើម្បីបន្តចំណងទាក់ទងជិតស្និទ្ធជាមួយអាស៊ាន។

ចំពោះកិច្ចការអាស៊ាន **ឯកឧត្តម** Mark Field បានលើកឡើងថា អង់គ្លេសត្រូវការគាំទ្រពីកម្ពុជាដើម្បីគោលដៅនៃការក្លាយជាដៃគូសន្ទនាជាមួយអាស៊ាន អោយបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ក្រោយពីចក្រភពអង់គ្លេសចេញពីសហភាពអឺរ៉ុប (Brexit)។ ឯកឧត្តម Mark Field បានបង្ហាញក្តីសង្ឃឹម និងជឿជាក់ថាអាស៊ានចាត់ទុកអង់គ្លេសជាដៃគូគួរអោយទុកចិត្តបាន។ ឯកឧត្តមបានបន្តទៀតថា ទំនាក់ទំនងរវាងប្រជាជនអាស៊ាន និងប្រជាជនរបស់ចក្រភពអង់គ្លេស មានភាពល្អប្រសើរ ជាពិសេសលើវិស័យអប់រំ ហើយនេះជាការងារអាទិភាពទីមួយដែល**ឯកឧត្តម** បានលើកឡើងនៅក្នុងសហប្រតិបត្តិការក្នុងក្របខណ្ឌរវាងអង់គ្លេស និងអាស៊ាន។

ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអង់គ្លេស និងកម្ពុជា ឯកឧត្តម Mark Field បានផ្តោតជាសំខាន់ទៅលើវិស័យនយោបាយ និងសេដ្ឋកិច្ច សន្តិសុខ ការពារជាតិ ភេរវកម្ម ការជួញដូរគ្រឿងញៀន និងការបន្តការងារទៅលើការបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនានា។

ឯកឧត្តមបានកត់សំគាល់ថា ទំនាក់ទំនងប្រជាជន និងប្រជាជន គឺជាផ្នែកមួយសំខាន់ ហើយអង់គ្លេសបានផ្តោតការយកចិត្តទុកដាក់លើបញ្ហានេះក្នុងការបន្តចំណងទាក់ទងរវាងប្រជាជនអង់គ្លេស និងប្រជាជនកម្ពុជា តាមរយៈវិស័យអប់រំ ហើយអង់គ្លេសមានគម្រោងបង្កើនចំនួនអាហារូបករណ៍ដល់យុវជន តាមរយៈកម្មវិធី Chevening Scholarship ដើម្បីផ្តល់ឱកាសអោយកាន់តែច្រើនថែមទៀតដល់យុវជនខ្មែរបានទៅសិក្សានៅចក្រភពអង់គ្លេស ។

**ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានសំដែងនូវសុទិដ្ឋិនិយមថា បំណងបន្តភាពជាដៃគូជាមួយអាស៊ាននឹងទទួលបានការគាំទ្រពីប្រទេសទាំងអស់ជាសមាជិកអាស៊ាន ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងអំណរគុណអង់គ្លេស ដែលនៅតែបន្តផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់ប្រទេសដែលមានការអភិវឌ្ឍតិចតួច (Least Developed Countries) រួមទាំងប្រទេសកម្ពុជាផងដែរ ។ ឯកឧត្តម Mark Field បានប្តេជ្ញាថានឹងបន្តផ្តល់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្មនេះ ទោះបីជាអង់គ្លេសចាកចេញពីសហភាពអឺរ៉ុប (Brexit) ក៏ដោយ ។

ចំពោះទិដ្ឋភាពនយោបាយ នៅកម្ពុជាថ្មីៗនេះ ឯកឧត្តម Mark Field បានកត់សំគាល់ថា កម្ពុជាបានឆ្លងកាត់ប្រវត្តិដ៏ជូរចត់មួយ តាំងពីសង្គ្រាមនៅវៀតណាមរហូតមកដល់របបប្រល័យពូជសាសន៍ និងឆ្លងកាត់សង្គ្រាមស៊ីវិល គឺមានបញ្ហាប្រឈមដែលត្រូវដោះស្រាយ ហើយអង់គ្លេសតែងតែត្រៀមខ្លួនជានិច្ចដើម្បីជួយដល់កម្ពុជានូវរាល់គ្រប់កិច្ចការអ្វីដែលអាចធ្វើទៅបាន ដើម្បីអោយប្រទេសកម្ពុជា មានការអភិវឌ្ឍប្រកបដោយស្ថិរភាព និងវិបុលភាព ។ ទោះបីឯកឧត្តមបានសំដែងនូវការខកចិត្តចំពោះការបោះឆ្នោតកន្លងហើយក៏ដោយ ក៏ឯកឧត្តមបានសម្តែងការគាំទ្រស្មារតីផ្សះផ្សារជាតិ ដែលបានបង្កើតឡើងដោយសម្តេចតេជោនាយករដ្ឋមន្ត្រី គឺឧត្តមក្រុមប្រឹក្សាផ្តល់ និងពិគ្រោះយោបល់ថ្នាក់ជាតិ ដែលរួមបញ្ចូលគ្រប់គណបក្សនយោបាយទាំងអស់ ដើម្បីផ្លាស់ប្តូរយោបល់គ្នា ដោយលោកបានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា ដំណើរការនេះជាសញ្ញាវិជ្ជមានប្រកបដោយស្មារតីផ្សះផ្សារជាតិ តទៅអនាគត ។

កិច្ចពិភាក្សា បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃសុក្រ ១៣ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៨